## ព័ត៌មានអំពីជំនួយហិរញ្ញវត្ថុ

យើងអាចជួយដោះស្រាយបញ្ហាវិក្កយបត្រផ្នែកវេជ្ជសាស្ត្ររបស់អ្នកបាន។
អ្នកអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបានជំនួយហិរញ្ញវត្ថុ

យើងផ្តល់ជូន៖

- ការថែទាំដោយឥតគិតថ្លៃ ឬក្នុងតម្លៃទាបសម្រាប់អ្នកដែលមានសិទ្ធិ
- គម្រោងបង់ប្រាក់រយៈពេលវែងដោយគ្មានការប្រាក់
- ជំនួយក្នុងការទទួលបានធានារ៉ាប់រងសុខភាព

**ស្វែងយល់បន្ថែមអំពីភាពអាចរកបាននៃកម្មវិធីទូទាត់បញ្ចុះតម្លៃ និងកម្មវិធីថែទាំសប្បុរសធម៌ របៀបដាក់ពាក្យ ព័ត៌មានអំពីសិទ្ធិទទួលបាន និងគោលនយោបាយស្តីពីការបង់ប្រាក់បញ្ចុះតម្លៃរបស់មន្ទីរពេទ្យ និងការថែទាំសប្បុរសធម៌ដោយចូលទៅកាន់គេហទំព័រ**
http://www.providence.org/FinancialHelp?

សិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុត្រូវបានកំណត់ដោយប្រើលក្ខណៈវិនិច្ឆ័យផ្សេងៗគ្នា រួមទាំងកន្លែងដែលអ្នករស់នៅ ទំហំគ្រួសារ និងប្រាក់ចំណូលរបស់អ្នក។ ម៉ាស៊ីនគិតលេខរបស់យើង (មាននៅលើគេហទំព័រខាងលើ) ប្រើប្រាស់ព័ត៌មានប្រភេទនេះ ដើម្បីជួយសម្រេចការទទួលបានសិទ្ធិដោយសក្តានុពល។ អាស្រ័យលើរដ្ឋ និងទំហំគ្រួសាររបស់អ្នក អ្នកទំនងជានឹងមានលក្ខណៈគ្រប់គ្រាន់ទទួលបានជំនួយ ប្រសិនបើប្រាក់ចំណូលគ្រួសារសរុបប្រចាំឆ្នាំរបស់អ្នកស្ថិតក្រោម 175-400% នៃកម្រិតភាពក្រីក្ររបស់សហព័ន្ធ។

ឬស្កេនកូដ QR៖
[រូបបញ្ចូលកូដ QR ដែលមានស្រាប់]

## ទាក់ទងទីប្រឹក្សាហិរញ្ញវត្ថុ

ស្វែងយល់ថាតើជម្រើសជំនួយហិរញ្ញវត្ថុណាខ្លះដែលមានសម្រាប់អ្នក និងទទួលបានជំនួយពីក្រុមរបស់យើង។
855-229-6466
ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពីម៉ោង 7 ព្រឹក ដល់ 5:30 ល្ងាច តាមម៉ោងស្តង់ដារតំបន់ប៉ាស៊ីហ្វិក

## តម្លាភាពនៃតម្លៃ

នៅឆ្នាំ 2018 មជ្ឈមណ្ឌលគម្រោង Medicare និង Medicaid បានចេញសេចក្តីណែនាំសម្រាប់មន្ទីរពេទ្យដើម្បីធ្វើតារាងបញ្ជីគិតថ្លៃស្តង់ដាររបស់ពួកគេលើបណ្តាញអនឡាញ។ ទោះជាយ៉ាងណាក៏ដោយ ថ្លៃសេវាមន្ទីរពេទ្យមិនផ្តល់បរិយាយពេញលេញអំពីអ្វីដែលអ្នកជំងឺនឹងបង់នោះទេ។ យើងសង្ឃឹមថា អ្នកនឹងប្រើកម្មវិធីប៉ាន់ស្មានតម្លៃដ៏មានប្រយោជន៍របស់យើងសម្រាប់ការចំណាយផ្ទាល់ខ្លួន ដោយចូលទៅកាន់គេហទំព័រ៖ https://www.providence.org/billing-support/price- estimate

បញ្ជីសេវាកម្មចាំបាច់ដែលមាននៅលើគេហទំព័រ៖ https://www.providence.org/billing- support/pricing-transparency

## ជួយបង់វិក្កយបត្ររបស់អ្នក

មានអង្គការឥតស៊ីមតិដើម្បីអ្នកប្រើប្រាស់ដោយឥតគិតថ្លៃ ដែលនឹងជួយអ្នកឱ្យយល់អំពីដំណើរការចេញវិក្កយបត្រ និងការទូទាត់។ អ្នកអាចទូរសព្ទទៅកម្មវិធី Health Consumer Alliance តាមលេខ 888-804-3536 ឬចូលទៅកាន់គេហទំព័រ៖ healthconsumer.org សម្រាប់ព័ត៌មានបន្ថែម។

បន្ថែមពីលើកម្មវិធីជំនួយហិរញ្ញវត្ថុរបស់ Providence មានជម្រើសផ្សេងទៀតដែលអាចរកបានដើម្បីជួយកាត់បន្ថយ និងលុបបំបាត់ការចំណាយលើសេវាថែទាំ។ យើងអាចជួយអ្នកក្នុងការដាក់ពាក្យសុំកម្មវិធី Medicare, Medicaid និងកម្មវិធីផ្សេងទៀត ដូចជាសិទ្ធិទទួលបានដោយសន្មតនូវគម្រោង Covered California និង កម្មវិធី Medi-Cal។

## កម្មវិធីបណ្ដឹងវិក្កយបត្រមន្ទីរពេទ្យ

កម្មវិធីបណ្ដឹងវិក្កយបត្រមន្ទីរពេទ្យ គឺជាកម្មវិធីរបស់រដ្ឋ ដែលពិនិត្យឡើងវិញ នូវការសម្រេចចិត្តរបស់មន្ទីរពេទ្យអំពីថាតើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបានជំនួយបង់វិក្កយបត្រមន្ទីរពេទ្យរបស់អ្នកដែរឬទេ។ ប្រសិនបើអ្នកជឿថា អ្នកត្រូវបានបដិសេធនូវជំនួយផ្នែកហិរញ្ញវត្ថុដោយមិនត្រឹមត្រូវ អ្នកអាចដាក់ពាក្យបណ្ដឹងទៅកម្មវិធីបណ្ដឹងវិក្កយបត្រមន្ទីរពេទ្យបាន។ ចូលទៅកាន់គេហទំព័រ HospitalBillComplaintProgram.hcai.ca.gov សម្រាប់ព័ត៌មានបន្ថែម និងដើម្បីដាក់ពាក្យបណ្ដឹង។

## ការបកប្រែ និងទម្រង់ដែលអាចចូលប្រើបាន

ជូនៈ ប្រសិនបើអ្នកត្រូវការជំនួយជាភាសារបស់អ្នក សូមទូរសព្ទទៅលេខ 1-888-311-9127 ឬទៅកាន់គ្លីនីកមន្ទីរពេទ្យ Providence ដែលនៅជិតអ្នក។ ការិយាល័យនេះបើកពីម៉ោង 8:00 ព្រឹក ដល់ 4:30 ល្ងាច ហើយមានទីតាំងនៅការិយាល័យប្រឹក្សាហិរញ្ញវត្ថុ។ ជំនួយ និងសេវាកម្មសម្រាប់ជនមានពិការភាព ដូចជាឯកសារជាអក្សរស្ទាប អក្សរពុម្ពធំ សំឡេង និងទម្រង់អេឡិចត្រូនិកដែលអាចចូលប្រើបានផ្សេងទៀតក៏មានផងដែរ។ សេវាកម្មទាំងនេះមិនគិតថ្លៃទេ។ ច្បាប់ចម្លងនៃឯកសារដែលបានបកប្រែអាចរកបាននៅលើគេហទំព័រ www.providence.org/financialhelp